THE SCHOOL DISTRICT OF PHILADELPHIA

**OFFICE OF THE SUPERINTENDENT**
440 North Broad Street
Philadelphia, PA 19130

**Dr. Tony B. Watlington Sr., Ed.D.**
Superintendent

ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០២៣

ជូនចំពោះ សិស្សានុសិស្ស មាតាបិតា និងក្រុមគ្រួសាររបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា៖

សប្តាហ៍នេះគឺជាសប្តាហ៍ដំបូងនៃការឈប់សម្រាកក្នុងរដូវក្តៅពេញសប្តាហ៍សម្រាប់សិស្សនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា។ ខណៈពេលដែលយើងនៅក្រសួងអប់រំកំពុងមមាញឹកក្នុងការរៀបចំសម្រាប់ជោគជ័យនៃឆ្នាំសិក្សា ២០២៣-២៤ យើងសង្ឃឹមថាលោកអ្នកឆ្លៀតយកឱកាសដើម្បីចូលរួមក្នុងសកម្មភាពដ៏មានតម្លៃ និងសប្បាយរីករាយមួយចំនួននៅរដូវក្តៅនេះ។ ខាងក្រោមនេះគឺជាព័ត៌មានមួយចំនួនដើម្បីជួយលោកអ្នកឱ្យសប្បាយក្នុងរដូវក្តៅនេះឱ្យបានពេញលេញ៖

**<u>បន្តការសិក្សាក្នុងរដូវក្តៅ</u>**

នៅថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០២៣ កម្មវិធីសិក្សាក្នុងរដូវក្តៅចាប់ផ្តើមសម្រាប់សិស្សរបស់ក្រសួងអប់រំដែលបានចុះឈ្មោះ។ នៅមានកន្លែងមួយចំនួនដែលនៅសល់ក្នុងកម្មវិធីសិក្សាក្នុងរដូវក្តៅរបស់យើង សម្រាប់ថ្នាក់ទី ១ ដល់ ទី ៧ នៅទីតាំងផ្សេងៗ។ កម្មវិធីនេះផ្តល់នូវការពង្រឹងការសិក្សាដោយផ្អែកលើគម្រោងសិក្សានៅពេលព្រឹក និងសកម្មភាពកម្សាន្តសប្បាយៗ និងដំណើរកម្សាន្តនៅពេលរសៀល ដែលគាំទ្រដល់ការរៀនសូត្រក្នុងវិស័យសិល្បៈ អត្តពលកម្ម និង វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) ។ សូមចូលទៅកាន់ គេហទំព័រកម្មវិធីក្នុងរដូវក្តៅ (Summer Programs website) របស់យើង ដើម្បីចុះឈ្មោះ។ ចាប់ពីថ្ងៃទី ២៦ ខែមិថុនា ដល់ ថ្ងៃទី ៣ ខែសីហា សិស្សានុសិស្សទាំងអស់ក៏អាចចូលរួមកម្មវិធីជួយបង្រៀនបន្ថែមនៅកន្លែងតែមួយរបស់ក្រសួងអប់រំដោយឥតគិតថ្លៃផងដែរ។ កម្មវិធីនេះគាំទ្រគណិតវិទ្យា ភាសាអង់គ្លេស វិទ្យាសាស្ត្រ សង្គមវិទ្យា និងការត្រៀមខ្លួនសម្រាប់ការធ្វើតេស្ត Keystone, PSSA, ACT, SAT និង PSAT ។ ស្វែងយល់បន្ថែមដោយចូលទៅកាន់ គេហទំព័រសម្រាប់ការជួយបង្រៀនបន្ថែម (tutoring website) របស់យើង។

មិនថាកូនរបស់លោកអ្នកចូលរួមក្នុងកម្មវិធីនារដូវក្តៅឬអត់ យើងសុំឱ្យលោកអ្នកគាំទ្រការបន្តការសិក្សារបស់ពួកគេនៅផ្ទះ។ សូមទៅកាន់បណ្ណាល័យក្នុងតំបន់របស់លោកអ្នក ដើម្បីខ្ចីសៀវភៅមួយចំនួនដែលមាននៅក្នុង បញ្ជីសម្រាប់អានក្នុងរដូវក្តៅ (summer reading list) របស់យើង។ បណ្ណាល័យជាតិសម្រាប់ផ្សព្វផ្សាយការអាន៖ ការណែនាំសម្រាប់មាតាបិតា (Reading Rockets: A Guide for Parents) គឺជាធនធានសម្រាប់ការអានដ៏មានប្រយោជន៍ផ្សេងទៀតសម្រាប់ឪពុកម្តាយ និងក្រុមគ្រួសារ ខណៈពេលដែលឯកសារនៃ ការណែនាំសម្រាប់គណិតវិទ្យាក្នុងរដូវក្តៅ (Summer Math Recommendations) នេះផ្តល់នូវគំនិតដើម្បីជួយសិស្សនៅគ្រប់កម្រិតថ្នាក់អនុវត្តជំនាញផ្នែកលេខ រាង ទិន្នន័យ និងគំរូនៅក្នុងពិភពលោកជុំវិញពួកគេ។ ហើយសូមចាំថា ទីក្រុងហ្វីឡាដែលហ្វ្យ៉ាក៏ផ្តល់នូវសកម្មភាព និងកម្មវិធីដែលមានតម្លៃទាប និងឥតគិតថ្លៃសម្រាប់ក្មេង និងយុវវ័យក្នុងរដូវក្តៅផងដែរ។ សូមចូលទៅកាន់គេហទំព័រ www.phila.gov/families សម្រាប់ទីតាំង និងព័ត៌មានបន្ថែម។

**<u>ការចុះឈ្មោះសិស្សថ្នាក់មុនមត្តេយ្យ ដល់ ទី ១២</u>**

សូមឆាប់ចុះឈ្មោះសិស្សថ្នាក់មត្តេយ្យ ដល់ ថ្នាក់ទី ១២ ព្រោះវានឹងជួយដល់ក្រសួងអប់រំឱ្យរៀបចំផែនការជាមុន និងធ្វើឱ្យប្រាកដថាសាលារៀនរបស់យើងបានរៀបចំដើម្បីស្វាគមន៍ក្មេងទាំងអស់នៅថ្ងៃចូលរៀនដំបូង។ សូមចុះឈ្មោះកូនរបស់លោកអ្នកឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដោយចូលទៅកាន់ គេហទំព័រចុះឈ្មោះសិស្សរបស់យើង (our student registration website)។ ក្រសួងអប់រំក៏ផ្តល់សេវាសម្រាប់ថ្នាក់មុនមត្តេយ្យ ពេញថ្ងៃ ដោយឥតគិតថ្លៃ ដល់ក្មេងដែលមានអាយុរៀនថ្នាក់មុនមត្តេយ្យជាង ៩,៥០០ នាក់ ដោយរួមដៃគូជាមួយកម្មវិធី Pre-K Counts, Head Start Partners និង PHL PreK ។ សម្រាប់ព័ត៌មានបន្ថែមអំពីកម្មវិធីមុនថ្នាក់មត្តេយ្យរបស់យើង និងដើម្បីចុះឈ្មោះ សូមចូលទៅកាន់ គេហទំព័រសម្រាប់កម្មវិធីមុនថ្នាក់មត្តេយ្យរបស់យើង (Early Childhood website)។

**អាហារក្នុងរដូវក្តៅ**

ក្រុមគ្រួសារនៅតែអាចទទួលអាហារដែលមានជីវជាតិសម្រាប់កូនរបស់លោកអ្នកក្នុងអំឡុងរដូវក្តៅ។ សូមចូលទៅកាន់ គេហទំព័រ www.phila.gov/food ឬហៅទូរស័ព្ទតាមរយៈខ្សែទូរស័ព្ទសម្រាប់អាហារក្នុងរដូវក្តៅ លេខ 215-770-4659 សម្រាប់បញ្ជីអាហារ និងកន្លែងផ្តល់អាហារទូទាំងទីក្រុង ឬផ្ញើសារ “FOOD” ឬ “COMIDA” ទៅ 304-304 ដើម្បីស្វែងរកកន្លែងផ្តល់អាហារដែលនៅជិតលោកអ្នកបំផុត។

**ការចាក់ថ្នាំបង្ការរោគ និងពិនិត្យរាងកាយ**

ក្រសួងអប់រំបានសហការជាមួយអង្គការមួយចំនួនដើម្បីធានាថាសិស្សានុសិស្សទាំងអស់នឹងមានភាពងាយស្រួលក្នុងការទទួលបានការពិនិត្យរាងកាយសម្រាប់កីឡា និងការចាក់ថ្នាំបង្ការរោគនៅរដូវក្តៅនេះ។ តាមរយៈការសហការរបស់យើងជាមួយ CityLife Health, Delaware Valley Community Health និង Black Doctors Consortium ថ្នាំបង្ការរោគ និងការពិនិត្យរាងកាយសម្រាប់កីឡា នឹងត្រូវបានផ្តល់ឱ្យសិស្សរបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ានៅទីតាំងមួយចំនួនរហូតដល់ខែកក្កដា និងខែសីហា។ សេវាពិនិត្យរាងកាយសម្រាប់កីឡា និងចាក់ថ្នាំបង្ការរោគ ត្រូវបានផ្តល់ឱ្យសិស្សទាំងអស់ដោយមិនគិតពីស្ថានភាពធានារ៉ាប់រងឡើយ។ ស្វែងរកកាលបរិច្ឆេទ និងទីតាំងចាក់ថ្នាំបង្ការរោគនៅរដូវក្តៅ និងព្រឹត្តិការណ៍ពិនិត្យរាងកាយ សូមមើលតម្រូវការឯកសារសម្រាប់អាយុ និងឯកសារសម្រាប់ព្រឹត្តិការណ៍ជាក់លាក់ និងធ្វើការណាត់ជួបតាមគេហទំព័រ www.philasd.org/vax។

តាមពិត មានអ្វីៗជាច្រើនដែលត្រូវធ្វើនៅរដូវក្តៅនេះ ក្នុងការរៀបចំសម្រាប់ឆ្នាំសិក្សាក្រោយ។ ខ្ញុំទន្ទឹងរង់ចាំការចាប់ដៃគូជាមួយលោកអ្នក ទោះបីជាក្នុងរដូវក្តៅក៏ដោយ នៅពេលដែលយើងបន្តធ្វើការដើម្បីរៀបចំសិស្សទាំងអស់ឱ្យស្រមៃ និងសម្រេចបាននូវអនាគតដែលពួកគេចង់បាន។ ហើយខ្ញុំរង់ចាំទទួលស្វាគមន៍កូនរបស់លោកអ្នកត្រឡប់មកវិញនៅ **ថ្ងៃអង្គារទី ៥ ខែ កញ្ញា** - ថ្ងៃចូលរៀនដំបូង។

ក្នុងភាពជាដៃគូ



Tony B. Watlington Sr., Ed.D.
អគ្គនាយកក្រសួងអប់រំ
ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា